ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

# ដំណឹងជ្រើសរើសគ្រូបង្រៀនទ្រឹស្តី

**យោង៖**
- កំណត់បង្ហាញលេខ ១៤៤/១៥ ប.ល/ស.វ.ស ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ របស់ផ្នែកបុគ្គលិក នៃ ស.វ.ស។
- ចំណារឯកភាព ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ២០១៥ របស់ឯកឧត្តមសាកលវិទ្យាធិការ នៃ ស.វ.ស។

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល គឺជាសាកលវិទ្យាល័យបណ្តុះបណ្តាលវិស័យសុខាភិបាល ដែលមានវ័យចំណាស់ជាងគេបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ត្រូវការជ្រើសរើស **គ្រូបង្រៀនទ្រឹស្តី និង ណែនាំអនុវត្តគ្រាប់ចំនួន ០៤រូប** បង្រៀនថ្នាក់ Master Orthodontic សម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ នៅមហាវិទ្យាល័យទន្តវេទនសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដែលត្រូវមានភារកិច្ច និង គុណវុឌ្ឍិ ដូចខាងក្រោម៖

| ក- ភារកិច្ច៖ | ខ- គុណវុឌ្ឍិ៖ |
|---|---|
| - ចូលរួមធ្វើបច្ចុប្បន្នភាពមេរៀន<br>- ផ្ទេរប្លង់មេរៀនតាមការណែនាំ របស់ ស.វ.ស<br>- ស្រាវជ្រាវឯកសារថ្មីៗដែលទាក់ទងនឹងមេរៀន<br>- រៀបចំសំនួរវាយតម្លៃនិស្សិត<br>- រៀបចំប្រគល់សំនួរ និង ចម្លើយគំរូ(បារ៉ែម) មក ម.វ.ទ ទៅតាមចំនួន និង កាលបរិច្ឆេទដែលបានកំណត់<br>- ចូលរួមវគ្គបណ្តុះបណ្តាលគរុកោសល្យ របស់ ស.វ.ស<br>- ចូលរួមតាមការចាត់តាំងរបស់ ម.វ.ទ និង ស.វ.ស | - មានកម្រិតសញ្ញាបត្រ Master Orthodontic ព្រមទាំងមានបទពិសោធន៍ក្នុងវិជ្ជាជីវៈ យ៉ាងតិច ០២ឆ្នាំ<br>- មាននិក្ខេបបទ<br>- មានបទពិសោធន៍ជាគ្រូណែនាំកម្មសិក្សា ឬ ណែនាំអនុវត្តគ្រាប់ យ៉ាងតិច ០២ឆ្នាំ<br>- មានចំណេះដឹងភាសាអង់គ្លេស ស្ទាត់ជំនាញ<br>- ចេះប្រើប្រាស់កម្មវិធី Ms. Office<br>- មានសីលធម៌រស់នៅល្អ ថ្លៃថ្នូរ ស្លូតបូត គោរពគ្នាទៅវិញទៅមក និង គោរពវិន័យ ស.វ.ស<br>- មានស្មារតីទទួលខុសត្រូវ និង តម្លាភាពក្នុងការបង្រៀន<br>- មានស្មារតីធ្វើការងារជាក្រុម និងមានភាពអំណត់អត់ធន់ក្នុងការងារ<br>- មានសុខភាពល្អ |

**ព័ត៌មានលម្អិត៖**

- បើបេក្ខជនមានចំណាប់អារម្មណ៍ **សូមទំនាក់ទំនងជាមួយផ្នែកបុគ្គលិក នៃ ស.វ.ស ដើម្បីបំពេញពាក្យសុំបង្រៀន ឬ អាចទាញយកទម្រង់ពាក្យសុំនេះនៅលើវេបសាយ** (www.uhs.edu.kh) **រួចផ្ញើមកផ្នែកបុគ្គលិក (បន្ទប់ M109) ឲ្យបានមុន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៥ វេលាម៉ោង១៦:០០រសៀលជាកំហិត។**
- អាសយដ្ឋានទំនាក់ទំនង៖ ឡូត៍លេខ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬ តាមទូរស័ព្ទលេខ 023 430 559 / 089 383 338 / 077 456 070 / 012 961 529 / 015 575 554 E-Mail: orn_samnang@uhs.edu.kh ។

**បញ្ជាក់៖**

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល រក្សាសិទ្ធិក្នុងការធ្វើបញ្ជីឈ្មោះជ្រើសរើសបេក្ខជន (Short List) និង កំណត់ ថ្ងៃខែសម្ភាសន៍ លើកពេលកែប្រែ និង លុបចោលការជ្រើសរើសក្នុងករណីមានភាពមិនប្រក្រតី។
- បេក្ខនារីត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥

**ប្រធានផ្នែកបុគ្គលិក**

ប៊ុន ធីរ៉ាត់